**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកោះកុង**

**រដ្ឋបាលស្រុកបូទុមសាគរ**

លេខ៖ ០០៧/២១ ស.ជ.ណ

ថ្ងៃពុធ ៦កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ស្រុកបូទុមសាគរ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១

## ជម្រាបជូន

**បងប្អូនប្រជាពលរដ្ឋ ដែលមានការពាក់ព័ន្ធក្នុងការសាងសង់ខ្ទមអាណាធិបតេយ្យ នៅចំណុចអូររពិល និងអូរយោយ៉ា ភូមិចំលងគោ ឃុំថ្មស ស្រុកបូទុមសាគរ ដែលទីតាំងនេះស្ថិតក្នុងតំបន់ការពារធម្មជាតិ នៃឧទ្យានជាតិបូទុមសាគរ**

**កម្មវត្ថុ ៖** ស្តីពីការចូលរួមសហការរុះរើខ្ទមអាណាធិបតេយ្យ ដែលលោក លោកស្រី បានសាងសង់នៅចំណុចអូររពិល និងអូរយោយ៉ា ភូមិចំលងគោ ឃុំថ្មស ស្រុកបូទុមសាគរ ដែលទីតាំងនេះស្ថិតក្នុងតំបន់ការពារធម្មជាតិ នៃឧទ្យានជាតិបូទុមសាគរ ខេត្តកោះកុង។

**យោង ៖**
- លិខិតលេខ: ១៩៦៣ ស.ជ.ណ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការទប់ស្កាត់ការកាប់ទន្ទ្រានយកដីដោយខុសច្បាប់ នៅក្នុងតំបន់ការពារធនធានធម្មជាតិនៅតាមខេត្តនានា
- លិខិតលេខ: ២៧១/២០ ស.ជ.ណ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្ត ស្តីពីការទប់ស្កាត់ការកាប់ទន្ទ្រានដីព្រៃខុសច្បាប់ នៅក្នុងតំបន់ការពារធនធានធម្មជាតិ
- របាយការណ៍ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ក្រុមការងារគណៈបញ្ជាការឯកភាពស្រុក ដែលបានចុះត្រួតពិនិត្យជាក់ស្តែង
- របាយការណ៍ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ក្រុមការងារគណៈបញ្ជាការឯកភាពស្រុកដែលបានចុះត្រួតពិនិត្យជាក់ស្តែង

តបតាមកម្មវត្ថុ និងយោងខាងលើ **រដ្ឋបាលស្រុក** មានកិត្តិយសសូមជម្រាបជូន លោក លោកស្រី ដែលជាម្ចាស់ខ្ទម ដែលបានសាងសង់នៅចំណុចអូររពិល និងអូរយោយ៉ា នៅភូមិចំលងគោ ឃុំថ្មស ស្រុកបូទុមសាគរ ដែលទីតាំងនេះស្ថិតក្នុងតំបន់ការពារធម្មជាតិ នៃឧទ្យានជាតិបូទុមសាគរ ខេត្តកោះកុង ជ្រាបថា៖

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ **រដ្ឋបាលស្រុកបូទុមសាគរ** បានចាត់ក្រុមការងារ ចុះត្រួតពិនិត្យ និងណែនាំដល់ប្រជាពលរដ្ឋដែលជាម្ចាស់ផ្ទះ និងខ្ទមអាណាធិបតេយ្យ ដែលបានសាងសង់ ក្នុងតំបន់ការពារធម្មជាតិ នៃឧទ្យានជាតិបូទុមសាគរ ឲ្យរុះរើចេញវិញ ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារក៏បានចុះត្រួតពិនិត្យទីតាំងនេះម្តងទៀត ដើម្បីពិនិត្យមើលថា តើបងប្អូនបានធ្វើការរុះរើផ្ទះ និងខ្ទមអាណាធិបតេយ្យ ចេញហើយឬនៅ។ ក្រោយពីធ្វើការចុះត្រួតពិនិត្យ ក្រុមការងារសង្កេតឃើញថា ខ្ទមមួយចំនួនត្រូវបានរុះរើចេញ ប៉ុន្តែនៅសល់មួយចំនួនដែលមិនទាន់បានធ្វើការរុះរើទេ។

បន្ទាប់មកនៅថ្ងៃ១១ ខែមករា ឆ្នាំ២០២១ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក ចុះអនុវត្តវិធានការរដ្ឋបាល ដោយធ្វើការរុះរើ ខ្ទមដែលប្រជាពលរដ្ឋបានសាងសង់រួច ព្រមទាំងបានធ្វើកិច្ចសន្យាជាមួយពួកគាត់ ដោយឲ្យពួកគាត់រុះរើផ្ទះ និងខ្ទមនោះចេញដោយខ្លួនឯងបានមួយចំនួន ហើយខ្ទមមួយចំនួនទៀតដែលនៅសល់មិនទាន់ធ្វើការរុះរើ ត្រូវធ្វើរុះរើដោយខ្លួនឯងជាក់ហ៊ត ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី ដែលមានពាក់ព័ន្ធក្នុងការសាងសង់ខ្ទមអាណាធិបតេយ្យនៅចំណុចអូររពិល និងអូរយោយ៉ា ភូមិចំលងគោ ឃុំថ្មស ស្រុកបូទុមសាគរ ដែលទីតាំងនេះស្ថិតក្នុងតំបន់ការពារធម្មជាតិ នៃឧទ្យានជាតិបូទុមសាគរ ខេត្តកោះកុង ត្រូវធ្វើការរុះរើចេញចាប់ពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១។

**រដ្ឋបាលស្រុកបូទុមសាគរ** សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ដែលមានការពាក់ព័ន្ធក្នុងការសាងសង់ខ្ទមអាណាធិបតេយ្យ នៅក្នុងតំបន់ ការពារធម្មជាតិ នៃឧទ្យានជាតិបូទុមសាគរ ទាំងអស់គ្នា ពិតជាមានសុឆន្ទៈ ចូលរួមសហការអនុវត្តន៍កុំបីខកខាន ។ ក្នុងករណី លោក លោកស្រី មិនបានចូលរួមសហការតាមសេចក្តីជូនដំណឹងនេះ រដ្ឋបាលស្រុកមិនទទួលខុសត្រូវ រាល់ការបាត់បង់ផលប្រយោជន៍ណាមួយឡើយ។

**អភិបាល**

ស៊ិន សោភ័ណ្ឌ

*ចម្លងជូន*
- សាលាខេត្តកោះកុង
- មន្ទីរ បរិស្ថានខេត្ត
- ក្រុមប្រឹក្សាស្រុក (ដើម្បីជូនជ្រាប)។
- សាលាឃុំថ្មស (ដើម្បីផ្សព្វផ្សាយ និង សហការអនុវត្តន៍)
- ឯកសារ-កាលប្បវត្តិ